00847865

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 09 / 2012
ម៉ោង (Time/Heure): 10 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E197/3

អង្គជំនុំជម្រះសាលាដំបូង
**Trial Chamber**
**Chambre de Premiere instance**
លេខៈ...២០...អ.វ.ត.ក/អ.ជ.ស.ដ

សាធារណៈ / Public

<u>សូមគោរពជូន</u>

**ឯកឧត្តម សាស្ត្រាចារ្យប្រធានមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត**

**<u>តាមរយៈ</u>**÷ ឯកឧត្តមប្រធានស្តីទីនៃការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**<u>កម្មវត្ថុ</u>**÷ សូមអញ្ជើញលោកវេជ្ជបណ្ឌិត **លឹម ស៊ីវុតថា** ប្រធានផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មកឆ្លើយបំភ្លឺអំពីស្ថានភាពសុខភាពរបស់លោក អៀង សារី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅព្រឹកថ្ងៃ សុក្រ ទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ នៅសាលសវនាការធំនៃ អ.វ.ត.ក ។

**<u>យោង</u>**÷ របាយការណ៍សុខភាពរបស់ជនជាប់ចោទ អៀង សារី ដែលបានចេញដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចុះថ្ងៃទី ១១, ១២, ១៣, ១៤ និងថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា៖ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ លោក អៀង សារី ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ អង្គជំនុំជម្រះបានទទួលរបាយការណ៍ជាបន្តបន្ទាប់ទាក់ទងនឹងស្ថានភាពសុខភាពរបស់លោក អៀង សារី ហើយនៅក្នុងរបាយការណ៍ចុងក្រោយចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២ បានបញ្ជាក់ថា លោក អៀង សារី តម្រូវឱ្យបន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យរហូតដល់ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២ រួចក្រុមគ្រូពេទ្យនឹងធ្វើការវាយតម្លៃលើស្ថានភាពសុខភាពរបស់គាត់ម្តងទៀត។

ដូច្នេះ ដើម្បីឱ្យអង្គជំនុំជម្រះយល់បានច្បាស់អំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ពាក់ព័ន្ធនឹងការចូលរួមសវនាការរបស់គាត់នោះ អង្គជំនុំជម្រះសាលាដំបូងសូមអញ្ជើញលោកវេជ្ជបណ្ឌិត **លឹម ស៊ីវុតថា** ដែលជាគ្រូពេទ្យព្យាបាលលោក អៀង សារី មកឆ្លើយបំភ្លឺនៅចំពោះមុខ

00847866

E197/3

អង្គជំនុំជម្រះនៅថ្ងៃ សុក្រ ទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ដោយចាប់ផ្តើមនៅវេលាម៉ោង ៩.០០ នាទី ព្រឹក នៅសាលសវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានអាសយដ្ឋាន ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ (អតីតខណ្ឌ ដង្កោ) រាជធានីភ្នំពេញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានមេត្តាអនុញ្ញាតឲ្យលោកវេជ្ជបណ្ឌិត **លឹម ស៊ីទុតថា** បានមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះតាមការគួរ។

សូមឯកឧត្តមប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ភ្នំពេញថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

E C C C E T C

និល ណុន